Department of Justice / **ក្រសួងយុត្តិធម៌**

---

សម្រាប់ចេញផ្សាយបន្ទាន់ CRT
ថ្ងៃព្រហស្បតិ៍ ទី 21 ខែមេសា ឆ្នាំ 2016 (202) 514-2007
WWW.JUSTICE.GOV TTY (866) 544-5305

# ក្រសួងយុត្តិធម៌បិទសំណុំរឿង បន្ទាប់ពីកំណែទម្រង់តុលានៅ Rhode Island ផ្តល់សិទ្ធិស្មើគ្នាដល់អ្នកនិយាយភាសាអង់គ្លេសនៅមានកម្រិត

រដ្ឋវ៉ាស៊ីងតោន៖ នៅថ្ងៃនេះក្រសួងយុត្តិធម៌បានប្រកាសបិទសំណុំរឿង ពាក់ព័ន្ធទៅនឹងការផ្តល់ជំនួយផ្នែកជំនាញភាសាអង់គ្លេសដល់អ្នកនិយាយភាសាអង់គ្លេសនៅមានកម្រិត (LEP) នៅតាមប្រព័ន្ធតុលាការរដ្ឋ បន្ទាប់ពីបានអនុវត្តដោយជោគជ័យលើកំណែទម្រង់តុលាការនៅ Rhode Island ។

ប្រព័ន្ធតុលាការនៅ Rhode Island និងក្រសួងយុត្តិធម៌បានដោះស្រាយដោយជោគជ័យលើការស៊ើបអង្កេតលើពាក្យបណ្តឹងរដ្ឋបាលទៅតាមផ្នែកទី VI នៃច្បាប់ស្តីពីសិទ្ធិពលរដ្ឋ ឆ្នាំ 1964 ដែលហាមឃាត់ការរើសអើងជាតិសាសន៍ ពណ៌សម្បុរ ឬដើមកំណើត ក្នុងការចូលរួមកម្មវិធីឬសកម្មភាពផ្សេងៗដែលរដ្ឋសហព័ន្ធបានផ្តល់មូលនិធិ។ ពាក្យបណ្តឹងបានចោទប្រកាន់ទៅលើតុលាការ Rhode Island ថាមិនបានផ្តល់អ្នកបកប្រែ និងសេវាជំនួយផ្នែកភាសាផ្សេងទៀត ដល់អ្នកមិនសូវចេះភាសាអង់គ្លេសនៅតុលាការ។ នៅឆ្នាំ 2012 បន្ទាប់ពីមានកិច្ចចរចារជាច្រើនរវាងតុលាការ Rhode Island និងក្រសួងយុត្តិធម៌ លោក Paul A. Suttell ប្រធានតុលាការកំពូលនៃ Rhode Island បានចេញផ្សាយ ដីការប្រតិបត្តិលេខ 2012-05 ស្តីពីសេវាបកប្រែភាសាក្នុងតុលាការដែលមានអ្នកបកប្រែមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងជំនួយផ្នែកភាសាផ្សេងទៀតដែលមានការអនុញ្ញាត និងមិនគិតថ្លៃចំពោះអ្នកដែលនិយាយភាសាអង់គ្លេសមានកម្រិត (LEP) ពេលចូលរួមក្នុងរាល់នីតិវិធីដំណើរការតុលាការ សេវាកម្ម និងកម្មវិធី។

ក្នុងឆ្នាំ 2014 ក្រសួងបានអនុម័តលើផែនការទទួលសេវាភាសា របស់តុលាការ Rhode Island និងគ្រប់ភាគីដែលបានចុះហត្ថលេខាលើ កិច្ចព្រមព្រៀងដោះស្រាយដោយស្ម័គ្រចិត្ត ដែលចាំបាច់សម្រាប់ការអនុវត្តជោគជ័យលើដីការប្រតិបត្តិ និងផែនការ មតិយោបល់ពីគណៈកម្មាធិការពាក់ព័ន្ធ ការអនុលោម

តាមផ្នែក VI និង ជំនួយបច្ចេកទេស និងការត្រួតពិនិត្យរយៈពេលពីរឆ្នាំ។ បច្ចុប្បន្ន ក្រសួងយុត្តិធម៌បានបិទសំណុំរឿងជាស្ថាពរ បន្ទាប់ពីតុលាការ Rhode Island បានបំពេញលក្ខខណ្ឌបញ្ចប់កិច្ចព្រមព្រៀង។

ក្រសួង និងតុលាការ Rhode Island ធ្វើការសហការគ្នាដើម្បីកែលម្អការប្រាស្រ័យទាក់ទងរវាងតុលាការជាមួយអ្នកនិយាយភាសាអង់គ្លេសមានកម្រិត។ ក្រៅពីការអនុម័តគោលនយោបាយទទួលបានសេវាភាសាពេញលេញមាននៅក្នុងដីការប្រតិបត្តិ សមិទ្ធិផលរបស់តុលាការរួមមាន៖

- ចាត់តាំងបុគ្គលិកមានសមត្ថភាពពេញលេញ ដើម្បីផ្តល់សេវាជូនអតិថិជនជននៅតុលាការ ក្រៅពីភាសាអង់គ្លេស
- បិទស្លាកសញ្ញាជាប្រាំមួយភាសាក្នុងតុលាការ ដោយផ្តល់យោបល់ជាសាធារណៈអំពីសិទ្ធិ ដើម្បីមានអ្នកបកប្រែដោយមិនគិតកម្រៃ
- តម្រូវអោយភាគីទាំងសងខាងទៅកាន់តុលាការរដ្ឋ ដើម្បីធ្វើរបាយការណ៍អំពីតម្រូវការទិន្នន័យអ្នកបកប្រែទៅតុលាការតាមរយៈតម្រូវការបំពេញតាមប្រព័ន្ធអេឡិចត្រូនិចថ្មី
- បកប្រែទម្រង់ និងមាតិការគេហទំព័រ ជាភាសានិយាយទូទៅផ្សេងទៀតក្នុង Rhode Island  រួមមានភាសាអេស្ប៉ាញ ប៉័រទុយកាល់ ខ្មែរ និងភាសាខេបវែខាន។
- បង្កើតសេចក្តីជូនដំណឹងច្រើនភាសាអំពីសិទ្ធិទទួលបានជំនួយផ្នែកភាសា និងការអនុម័តច្បាប់តុលាការ ដែលត្រូវការសេវាជូនដំណឹងដល់ជនជាប់ចោទនីមួយៗក្នុងពេលដំណើការក្តី និង
- បង្កើតសេវាភាសាគោលនយោបាយពាក្យបណ្តឹងមួយ និងបង្ហោះទម្រង់ពាក្យបណ្តឹងពីរ បីភាសាក្នុង [វិបសាយរបស់តុលាការ ]របស់តុលាក្នុងការិយាល័យក្រឡាបញ្ជីតុលាការ និងការិយាល័យអ្នកបកប្រែ

លោក វ៉ានីតា ហ្គុបតា ជំនួយការអនុប្រធានអគ្គមេធាវី និងជាប្រធាននាយកដ្ឋានសិទ្ធិពលរដ្ឋ នៃក្រសួងយុត្តិធម៌បានមានប្រសាសន៍ថា “សិទ្ធិដើម្បីទទួលបានយុត្តិធម៌ ទាមទារឲ្យប្រជាពលរដ្ឋគ្រប់រូប រួមទាំងអ្នកចេះភាសាអង់គ្លេសមានកម្រិត មានសិទ្ធិចូលរួមដោយពេញលេញ និងដោយស្មើភាពក្នុងតុលាការ”។ លោកបន្ថែម “យើងសូមកោតសរសើរដល់ប្រធានចៅក្រម Suttell និងបុគ្គលិក ក្នុងការិយាល័យរដ្ឋបាលតុលាការរដ្ឋ ចំពោះកិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើតឲ្យមានសិទ្ធិស្មើគ្នាដើម្បីទទួលបានយុត្តិធម៌ពិតប្រាកដសម្រាប់ប្រជាពលរដ្ឋទាំងអស់នៅ Rhode Island ”។

បញ្ហារបស់ Rhode Island  ត្រូវបានដោះស្រាយដោយ លោក Paul M. Uyehara មេធាវីនៃសហព័ន្ធសម្រប សម្រួល និងកិច្ចការច្បាប់ (FCS) ផ្នែកសិទ្ធិពលរដ្ឋ ។

ពាក្យបណ្ដឹងត្រូវបានដោះស្រាយដែលជាផ្នែកមួយនៃការចូលរួមរបស់ FCS ដើម្បីធានាថាតុលាការរដ្ឋ អនុវត្តតាមតម្រូវការសិទ្ធិទទួលបានភាសានៃផ្នែក VI ។ ដើម្បីធានាថាបុគ្គលនិយាយភាសាអង់គ្លេសមាន កម្រិត មិនត្រូវបានទទួលភាពអយុត្តិធម៌ ដោយសារតែតុលាការមិនបានផ្ដល់សេវាភាសា ក្រុមការងាររបស់ តុលាការ FCS ផ្ដល់គោលនយោបាយណែនាំ និងជំនួយបច្ចេកទេសដល់ប្រព័ន្ធតុលាការរដ្ឋ និងអនុវត្ត សកម្មភាពទូទាំងប្រទេស។

សម្រាប់ព័ត៌មានបន្ថែមអំពី FCS និង ផ្នែក VI សូមទស្សនា https://www.justice.gov/crt/fcs។ ព័ត៌មានបន្ថែមទាក់ទង LEP សូមទស្សនា http://www.lep.gov/index.htm.

\# # #

16-XXX

ហាមឆ្លើយសារនេះ។ ប្រសិនបើលោកអ្នកមានសំណួរ សូមផ្ញើរសារ ឬទូរស័ព្ទមកការិយាល័យកិច្ចការ សាធារណៈតាមរយៈលេខ 202-514-2007។